**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គបុរេជំនុំជម្រះ**
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ
លេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១៤)
ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០០៨
និង
លេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១៥)
ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៨

## <u>នីតិវិធីជំនុំជម្រះរឿងព្រហ្មទណ្ឌ</u>

**(ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង ៩ៈ០០ ព្រឹក)**

**សវនាការសាធារណៈ**

**<u>ការកំណត់ពេលវេលាៈ</u>**

**វគ្គទី១ៈ** ម៉ោង៩ៈ០០-១០ៈ១៥
(សម្រាកៈ ១៥ នាទី)

**វគ្គទី២ៈ** ម៉ោង១០ៈ៣០-១១ៈ៤៥
(សម្រាករយៈពេល ១ ម៉ោង សំរាប់អាហារថ្ងៃត្រង់)

**វគ្គទី៣ៈ** ម៉ោង១២ៈ៤៥-២ៈ០០
(សម្រាករយៈពេល១៥ នាទី)

**វគ្គទី៤ៈ** ម៉ោង២ៈ១៥-៤ៈ០០

**<u>៨ៈ៤៥ នាទីព្រឹក</u>**

- សាធារណៈជនមានវត្តមានក្នុងសាលសវនាការ

- សហមេធាវី និងជនត្រូវចោទមានវត្តមានក្នុងសាលសវនាការ

- សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីមានវត្តមានក្នុងសាលសវនាការ

- ក្រឡាបញ្ជីជាតិប្រកាសបទបញ្ជាផ្ទៃក្នុងសម្រាប់ថ្ងៃសវនាការ

- កណ្តឹងលើកទី១០: សហព្រះរាជអាជ្ញាចូលកាន់សាលសវនាការ

- អ្នកសារព័ត៌មានចំនួន ៤រូប (អ្នកថតរូប ២នាក់ និងថតវីដេអូ ២នាក់) ចូលថតរូបក្នុង សាលសវនាការ។

## ៩០:០០ នាទីព្រឹក

-កណ្តឹងលើកទី២០: ក្រឡាបញ្ជីអញ្ជើញភ្ញៀវទាំងអស់អោយក្រោកឈរ ដោយស្រែកថា "តុលាការ" ក្រុមប្រឹក្សាជំនុំជម្រះចូលក្នុងសាលសវនាការ

-ប្រធានបង្គាប់អោយអង្គុយចុះ។

## ប្រធានប្រកាស

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ ថ្ងៃនេះ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រកាសបើកសវនាការ ដើម្បីជំនុំជម្រះរឿងព្រហ្មទណ្ឌចំនួនពីរ គឺសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១៤) ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០០៨ និងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១៥) ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលរួមមាន ៖

- ជនត្រូវចោទឈ្មោះ **ខៀវ សំផន** ហៅ **ហែម** សញ្ជាតិខ្មែរ ភេទ ប្រុស កើតថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅឃុំរំចេក ស្រុករំដួល ខេត្តស្វាយរៀង ប្រទេសកម្ពុជា ទីលំនៅមុនពេលចាប់ខ្លួន នៅភូមិកូនខ្លុង សង្កាត់អូរតាវ៉ៅ ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន ប្រទេសកម្ពុជា ឪពុកឈ្មោះ **ខៀវ ឡុង** (ស្លាប់) ម្តាយឈ្មោះ **ប៉ោ គង់** (ស្លាប់)។

- ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥, មាត្រា៦, មាត្រា ២៩(ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤ ។

- មេធាវីការពារក្តី: - លោក **ស សុវាន**

- លោក Jacques VERGES

- មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:

លោក ហុង គឹមសួន

លោក ឡោ ជុនធី

លោក នី ចាន់ឌី

លោក គង់ ពិសី

លោក យុង ផានិត

លោក គឹម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី Silke STUDZINSKY (ស៊ីល ស្ទូហ្ស៊ិនស្គី)

លោកស្រី Martine JACQUIN (ម៉ាទីន ស្សាក់គីន)

លោក Philippe CANNONE (ហ្វីលីព កានូន)

លោក Pierre Olivier SUR (ព្យែរ អូលីវីយេ សៀរ)

លោកស្រី Elizabeth RABESANRATANA (អេលីស្សាបេត រ៉ាបេសាន់រតនា)

លោក Olivier BAHOUGNE (អូលីវីយេ បាហ៊ូញ)

លោក David BLACKMAN (ដេវីដ ប្លេកមេន)

## <u>ប្រធានស្តីទីក្រឡាបញ្ជី</u>

តើអ្នកចូលរួមសវនាការមានវត្តមានគ្រប់ចំនួនហើយឬនៅ ?

## <u>ប្រធានប្រកាស</u>

ការជំនុំជម្រះថ្ងៃនេះ មានសមាសភាពដូចតទៅ:

១. លោក **ប្រាក់ គឹមសាន** **ប្រធាន**

២. លោក Rowan DOWNING ចៅក្រម

៣. លោក **ន័យ ថុល** ចៅក្រម

៤. លោកស្រី KatinKa LAHUIS ចៅក្រម

៥. លោក **ហួត វុទ្ធី** ចៅក្រម

- លោក **ម៉ែន ពេជ្រសាលី** ចៅក្រមបំរុង

- **ក្រឡាបញ្ជី:** កញ្ញា **សរ ច័ន្ទរ៉ាត**

លោកស្រី Anne Marie BURNS

- **តំណាងអយ្យការ:**

លោក **យ៉េត ចរិយា** សហព្រះរាជអាជ្ញារង

លោក **Vicent de WILDE d'ESTMAEL** សហព្រះរាជអាជ្ញារង

## <u>ប្រធានអញ្ជើញជនត្រូវចោទមកឈរមុខចៅក្រម</u>

លោកឈ្មោះអ្វី? មានឈ្មោះហៅក្រៅទេ? អាយុប៉ុន្មាន? សញ្ជាតិអ្វី? កើតនៅភូមិណា? ឃុំណា? ស្រុកណា? ខេត្តណា? មុខរបរធ្វើអ្វី? ទីលំនៅមុនពេលចាប់ខ្លួននៅឯណា? ឪពុកឈ្មោះអ្វី? ម្តាយឈ្មោះអ្វី? ប្រពន្ធឈ្មោះអ្វី? មានកូនប៉ុន្មាននាក់? តើមានពឹងអ្នកការពារ ឬ មេធាវីដែរឬទេ? ហើយមានឈ្មោះអ្វី?

**<u>ប្រធានប្រាប់សិទ្ធិដល់ជនជាប់ចោទ (វិធាន ២១-១ (ឃ))</u>**

*អនុលោមតាមវិធាន២១-១ (ឃ) នៃវិធានផ្ទៃក្នុង ជនត្រូវចោទ* ***ខៀវ សំផន***

*- លោកត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់លោក មិនទាន់ត្រូវបាន រកឃើញ*

*- លោកមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន*

*- លោកមានសិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់លោក និង*

*- លោកមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប។*

**<u>សំណុំរឿងទី១</u>**ៈ **លេខ** ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ១៤) ស្តីពីៈ

**បណ្តឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធសំណើសុំដោះលែងឲ្យមានសេរីភាពៈ**

**<u>ប្រធានអញ្ជើញចៅក្រមរបាយការណ៍អានរបាយការណ៍</u>**

- ចៅក្រម **ហួត វុទ្ធី** (ចៅក្រមជាតិ) អានរបាយការណ៍

**<u>ប្រធានអញ្ជើញជនត្រូវចោទក្រោកឈរ</u>**

ប្រធានសួរជនត្រូវចោទ ថាតើលោកចង់និយាយទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ដោយខ្លួនឯង រឺក៏ចង់អោយសហមេធាវីរបស់លោកនិយាយក្នុងនាមអោយលោក។

**<u>ប្រធានអញ្ជើញសហមេធាវីធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបទាក់ទងនឹង បញ្ហាសុំដោះលែងឲ្យមានសេរីភាព</u>**

( រយៈពេល **១ ម៉ោង** សម្រាប់សហមេធាវីតាមពេលសមស្រប)

**<u>ប្រធានអញ្ជើញសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេប</u>**

( រយៈពេល **១ ម៉ោង** សម្រាប់សហព្រះរាជអាជ្ញាតាមពេលសមស្រប)

**ប្រធានអនុញ្ញាតអោយមេធាវីការពារក្ដីធ្វើការឆ្លើយតប**

(រយៈពេល **១៥ នាទី** សម្រាប់សហមេធាវីការពារក្ដីធ្វើការឆ្លើយតប)

**ចៅក្រមអាចសួរសំណួរ**

**ប្រធានសួរជនត្រូវចោទថាតើមានអ្វីចង់បន្ថែមដែរឬទេ**

**សំណុំរឿងទី២០**: **លេខ** ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ១៥) ស្ដីពី:

**បណ្ដឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្ដីពីការបន្ដរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន:**

**ប្រធានអញ្ជើញចៅក្រមរបាយការណ៍អានរបាយការណ៍**

- ចៅក្រម **ហួត វុទ្ធី** (ចៅក្រមជាតិ) អានរបាយការណ៍

**ប្រធានអញ្ជើញជនត្រូវចោទក្រោកឈរ**

ប្រធានសួរជនត្រូវចោទ ថាតើលោកចង់និយាយទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍ដោយខ្លួនឯង រឺក៏ចង់អោយសហមេធាវីរបស់លោកនិយាយក្នុងនាមអោយលោក?

**ប្រធានអញ្ជើញសហមេធាវីធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេបទាក់ទងនឹងបញ្ហាការបន្ដរយៈពេលនៃឃុំខ្លួនបណ្ដោះអាសន្ន**

( រយៈពេល **១ ម៉ោង** សម្រាប់សហមេធាវីតាមពេលសមស្រប)

**ប្រធានអញ្ជើញសហព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេប**

( រយៈពេល **១ ម៉ោង** សម្រាប់សហព្រះរាជអាជ្ញាតាមពេលសមស្រប)

**ប្រធានអនុញ្ញាតអោយមេធាវីការពារក្ដីធ្វើការឆ្លើយតប**

(រយៈពេល **១៥ នាទី** សម្រាប់សហមេធាវីការពារក្ដីធ្វើការឆ្លើយតប)

**ចៅក្រមអាចសួរសំណួរ**

**ប្រធានសួរជនត្រូវចោទថាតើមានអ្វីចង់បន្ថែមដែរឬទេ**

**ប្រធានជូនព័ត៌មានទាក់ទងអំពីការប្រកាសសាលដីកា**

**តាមសំណើរបស់ភាគីណាមួយ អង្គបុរេជំនុំជម្រះបន្ដសវនាការជាអសាធារណៈ**

**ប្រធានបង្គាប់ឲ្យក្រុមការពារនាំជនត្រូវចោទត្រឡប់ទៅមន្ទីរឃុំឃាំងវិញ**

**ប្រធានប្រកាសបិទសវនាការ ។**